**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

នាយកដ្ឋានបុគ្គលិក គសហវ
ចូល
លេខ......0805......
ថ្ងៃទី......30/3/23......
ម៉ោង......4:00......

លេខ [illegible] សហវ.ណ.សា.វិ.ស.ប ថ្ងៃអង្គារ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០២៣

**គោរពជូន**

- **ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល**
- **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន**

**កម្មវត្ថុ :** សំណើសុំចាត់បញ្ជូនមន្ត្រីរាជការ ចូលរៀនវគ្គបណ្តុះបណ្តាល "**ជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង**" នៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា ក្នុងគោលដៅពង្រឹងពង្រីកសមត្ថភាព និងលើកកម្ពស់ការយល់ដឹងប្រកបដោយគុណភាព និងមានលក្ខណៈស៊ីជម្រៅជូនមន្ត្រីរាជការគោលដៅ ក្នុងមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមស្មារតីផែនការយុទ្ធសាស្ត្រស្តីពី ការកសាង និង ការអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី ៤, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំបើកវគ្គបណ្តុះបណ្តាល "**ជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង**" លើជំនាញបច្ចេកទេសចំនួន ៤ គឺ *(១). ជំនាញគណនេយ្យសាធារណៈ ផ្នែករដ្ឋទេយ្យចំណូល, (២). ជំនាញគណនេយ្យសាធារណៈ ផ្នែករដ្ឋទេយ្យបុរេប្រទាន, (៣). ជំនាញការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, និង (៤). ជំនាញគ្រប់គ្រងវិនិយោគសាធារណៈ*។ វគ្គបណ្តុះបណ្តាលនេះ មានរយៈពេលសរុបពី **៤៥ ម៉ោង** ដល់ **៨១ ម៉ោង** ទៅតាមជំនាញនីមួយៗ និង ត្រូវប្រព្រឹត្តទៅដោយចែកជា **៤ លើក** នៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ, ពីម៉ោង ១៤:០០នាទី ដល់ ១៧:១៥នាទី) ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ***ចាត់បញ្ជូនមន្ត្រីរាជការ ស្របតាមចំនួន និង កាលបរិច្ឆេទ ដូចមានក្នុងឯកសារជូនភ្ជាប់មកជាមួយ*** ដើម្បីចូលរៀនក្នុងវគ្គបណ្តុះបណ្តាលខាងលើ និងសូមបញ្ជូនមកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២៣ ។ *មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឱ្យមកទទួលការបណ្តុះបណ្តាល ត្រូវតែជាមន្ត្រីរាជការដែលមិនធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីឆ្នាំ ២០១៨ ដល់ ២០២២ និង ត្រូវមានលក្ខណៈវិនិច្ឆ័យផ្សេងទៀតស្របតាមសេចក្តីជូនដំណឹងដូចមានក្នុងឯកសារជូនភ្ជាប់ ។*

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីប្រចាំការនាយករដ្ឋមន្ត្រី និង ជារដ្ឋលេខាធិការ**

បណ្ឌិតសភាចារ្យ **ម៉ាន សាហ៊ុម**

***ចម្លងជូន:***

- *ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ*
  *"ដើម្បីជូនជ្រាប"*
- *ឯកសារ-កាលប្បវត្តិ*

31/03/23

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**តារាងបែងចែកមន្ត្រីរាជការ និង កាលបរិច្ឆេទចូលរៀន**

**វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង (Certificate Program)**

**នៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០២៣**

# អគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**១. ចំនួនមន្ត្រីរាជការដែលត្រូវអញ្ជើញ**

| ល.រ | ជំនាញឯកទេស | កម្មវិធីបណ្តុះបណ្តាល កម្រិតទី ១ | | | កម្មវិធីបណ្តុះបណ្តាល កម្រិតទី ២ |
|---|---|---|---|---|---|
| | | វគ្គទី ១ | វគ្គទី ២ | វគ្គទី ៣ | វគ្គទី ៤ |
| ១ | ជំនាញគណនេយ្យសាធារណៈ-ផ្នែករដ្ឋទេយ្យបុរេប្រទាន | ១ | ១ | | 0 |
| ២ | ជំនាញគណនេយ្យសាធារណៈ-ផ្នែករដ្ឋទេយ្យចំណូល | 0 | 0 | - | 0 |
| ៣ | ជំនាញគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ | ១ | ១ | | ១ |
| ៤ | ជំនាញគ្រប់គ្រងវិនិយោគសាធារណៈ | - | | 0 | - |
| **សរុបមន្ត្រីរាជការដែលត្រូវអញ្ជើញ** | | ២ | ២ | ០ | ១ |

**បញ្ជាក់ ÷** មន្ត្រីរាជការដែលនឹងត្រូវចាត់បញ្ជូនឱ្យចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាល កម្រិតទី ១ និង កម្រិតទី ២ *ត្រូវតែជាមន្ត្រីរាជការដែលមិនធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីឆ្នាំ ២០១៨ ដល់ ២០២២ និង ត្រូវមានលក្ខណៈវិនិច្ឆ័យផ្សេងទៀតស្របតាមសេចក្តីជូនដំណឹងដូចមានក្នុងឯកសារជូនភ្ជាប់។*

**២. កាលបរិច្ឆេទចូលរៀន**

វគ្គទី ១ : ចាប់ផ្តើមថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២៣ គ្រោងបញ្ចប់ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២៣ ។

វគ្គទី ២ : ចាប់ផ្តើមថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០២៣ គ្រោងបញ្ចប់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ ។

វគ្គទី ៣ : ចាប់ផ្តើមថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០២៣ គ្រោងបញ្ចប់ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២៣ ។

វគ្គទី ៤ : ចាប់ផ្តើមថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០២៣ គ្រោងបញ្ចប់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២៣ ។

ថ្ងៃ ចន្ទ ១៤រោច ខែ ផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣

**វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

(គម្រូ 01)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង** ..............................

**អង្គភាព** ..............................

រូបថត
4 x 6

## ប្រវត្តិរូបសង្ខេប

**ព័ត៌មានផ្ទាល់ខ្លួន**

- គោត្តនាម និងនាម.................................... អក្សរពុម្ពឡាតាំង.................................... ភេទ : ☐ស្រី ☐ប្រុស
- កើតថ្ងៃទី ....... ខែ ....... ឆ្នាំ ........... សញ្ជាតិ ........... កើតនៅភូមិ .................. ឃុំ/សង្កាត់ ..............................

ក្រុង/ស្រុក/ខណ្ឌ .................................... រាជធានី/ខេត្ត ....................................

- លេខទូរស័ព្ទផ្ទាល់ខ្លួន .................... លេខទូរស័ព្ទក្នុងករណីបន្ទាន់ .................... អ៊ីម៉ែល ....................

និងលេខទូរស័ព្ទរបស់អង្គភាព ឬនាយកដ្ឋានបុគ្គលិក.................................... ឬ ផ្សេងៗ: ....................

**អាសយដ្ឋានបច្ចុប្បន្ន:** ..............................................................................

**ស្ថានភាពបច្ចុប្បន្ន**

- ធ្វើការនៅក្រសួង/ ស្ថាប័ន/ អង្គភាព .................................... មុខតំណែងបច្ចុប្បន្ន ....................

ក្របខណ្ឌ .................... ឬ ឋានន្តរស័ក្តិបច្ចុប្បន្ន (ករណីកងកម្លាំងប្រដាប់អាវុធ:ឋានន្តរស័ក្តិ) ....................

អត្តលេខមន្ត្រីរាជការ .................................... លេខអត្តសញ្ញាណប័ណ្ណ ....................

**អតីតភាពការងារ (គិតពីថ្ងៃចូលបម្រើការងារក្នុងមុខងារសាធារណៈ ឬ ការងាររដ្ឋ):** ចំនួន .................... ឆ្នាំ

**ភាសាបរទេស:** ☐អង់គ្លេស ☐ចិន ☐បារាំង ☐ជប៉ុន ☐ផ្សេងៗ: ....................

**កម្រិតវប្បធម៌ទូទៅ:** ..............................................................................

សញ្ញាបត្រដែលទទួលបាន .................................... ថ្ងៃខែឆ្នាំបញ្ចប់ការសិក្សា ....................

**កម្រិតបណ្តុះបណ្តាលចុងក្រោយ** .................................... គ្រឹះស្ថានសិក្សា ....................

ទីកន្លែងសិក្សា .................................... សញ្ញាបត្រដែលទទួលបាន ....................

ជំនាញសិក្សា .................................... ថ្ងៃខែឆ្នាំបញ្ចប់ការសិក្សា ....................

**ព័ត៌មានពាក់ព័ន្ធការងារក្នុងមុខងារសាធារណៈ:**

| ថ្ងៃខែឆ្នាំចូលបំពេញការងារ | ថ្ងៃខែឆ្នាំបញ្ចប់ការងារ | ក្រសួង-ស្ថាប័ន | អគ្គនាយកដ្ឋាន ឬ អង្គភាព ឬ មន្ទីរ | នាយកដ្ឋាន | មុខតំណែង |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**ព័ត៌មានពាក់ព័ន្ធការងារក្នុងមុខងារហិរញ្ញវត្ថុសាធារណៈ:**

| ថ្ងៃខែឆ្នាំចូលបំពេញការងារ | ថ្ងៃខែឆ្នាំបញ្ចប់ការងារ | ក្រសួង-ស្ថាប័ន | អគ្គនាយកដ្ឋាន ឬ អង្គភាព ឬ មន្ទីរ | នាយកដ្ឋាន | តួនាទី |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញក្នុងប្រវត្តិរូបខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន ។

**បានឃើញ និង បញ្ជាក់ថា**
ព័ត៌មានដែល លោក/ លោកស្រី ..............................
បានអះអាងខាងលើពិតជាត្រឹមត្រូវប្រាកដមែន។
ថ្ងៃ ........................ ខែ ............... ឆ្នាំ ............... ព.ស. .....
.......... ថ្ងៃទី ............ ខែ ............ ឆ្នាំ ២០២៣
**ប្រធានអង្គភាព**

ឈ្មោះ ..............................

ថ្ងៃ ........................ ខែ ............... ឆ្នាំ ............... ព.ស. .....
.......... ថ្ងៃទី ............ ខែ ............ ឆ្នាំ ២០២៣
ហត្ថលេខាសាមីខ្លួន

ឈ្មោះ ..............................

<u>**បញ្ជាក់:**</u> សូមភ្ជាប់មកជាមួយនូវ÷

(១). ប្រវត្តិរូបសង្ខេប (បញ្ជាក់ពីអង្គភាពគ្រប់គ្រងបុគ្គលិក ឬ ប្រធានអង្គភាព, តាមគំរូដូចមានជូនភ្ជាប់),
(២). រូបថតថ្មី ៤x៦ ចំនួន ២ សន្លឹក,
(៣). លិខិតតាំងស៊ប់ក្នុងក្របខណ្ឌ ឬ ប្រកាសទទួលស្គាល់មន្ត្រីជាប់កិច្ចសន្យា,
(៤). លិខិតតែងតាំងក្នុងមុខតំណែងបច្ចុប្បន្ន (មុខតំណែងក្នុងមុខងារសាធារណៈ),
(៥). ប្រកាស ឬ សេចក្តីសម្រេច ឬ ដីកា ដែលបញ្ជាក់ពីការតែងតាំងជា រដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង រដ្ឋទេយ្យករចំណូល រដ្ឋទេយ្យករចំណូលរង ក្រុមការងារគ្រប់គ្រងវិនិយោគសាធារណៈ ក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, ឬ **សេចក្តីបញ្ជាក់របស់ប្រធានអង្គភាព ដែលបញ្ជាក់ថា កំពុងបម្រើការងារពាក់ព័ន្ធនឹងជំនាញដែលត្រូវសិក្សា** (តាមគំរូដូចមានជូនភ្ជាប់),
(៦). អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សំបុត្រកំណើត (ថតចម្លង), និង
(៧). លិខិតចាត់បញ្ជូន ឱ្យមកទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (លិខិតឆ្លើយតបរបស់សាមីអង្គភាព) ។

- *ប្រធានអង្គភាព សំដៅដល់ប្រធាននាយកដ្ឋានបុគ្គលិក ឬ ប្រធានអង្គភាពដែលទទួលបន្ទុកគ្រប់គ្រងបុគ្គលិក ឬ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ។*

(គម្រូ 02)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង** ..............................................................

**អង្គភាព** ..............................................................

**សេចក្តីបញ្ជាក់**

សូមបញ្ជាក់ថាលោក/លោកស្រី .................................................... អក្សរឡាតាំង ..................................................

ភេទ ........... សញ្ជាតិ ............ ថ្ងៃខែឆ្នាំកំណើត ......................... តួនាទីបច្ចុប្បន្ន÷ ........................................

កំពុងបម្រើការងារនៅ÷ ...................................................................................................................

ពាក់ព័ន្ធនឹងជំនាញ÷ ......................................................................................................................

ខ្ញុំសូមធានាអះអាងថា ព័ត៌មានខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន ។

ថ្ងៃ ......................... ខែ ............... ឆ្នាំ.................... ព.ស.........

....................... ថ្ងៃទី ......... ខែ......... ឆ្នាំ ២០២៣

**ប្រធានអង្គភាព**

*- ប្រធានអង្គភាព សំដៅដល់ប្រធាននាយកដ្ឋានបុគ្គលិក ឬ ប្រធានអង្គភាពដែលទទួលបន្ទុកគ្រប់គ្រងបុគ្គលិក ឬ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ។*

(គម្រូ 03)

ក្រសួង ស្ថាប័ន ____________

# បញ្ជីឈ្មោះមន្ត្រីរាជការ

## ចូលរៀនវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ឆ្នាំ ២០២៣

| ល.រ | ឈ្មោះជាអក្សរខ្មែរ | ឈ្មោះជាអក្សរឡាតាំង | ភេទ | តួនាទី | អង្គភាព | លេខទូរស័ព្ទ | ជំនាញសិក្សា | វគ្គសិក្សា |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| ៧ | | | | | | | | |
| ៨ | | | | | | | | |
| ៩ | | | | | | | | |

បានឃើញ និង ឯកភាព

ថ្ងៃ ____________ ខែ ________ ឆ្នាំ ________ ព.ស. ____

____________ ថ្ងៃទី ____ ខែ ____ ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីក្រសួង/អគ្គនាយក**

ថ្ងៃ ____________ ខែ ________ ឆ្នាំ ________ ព.ស. ____

____________ ថ្ងៃទី ____ ខែ ____ ឆ្នាំ ២០២៣

**អ្នករៀបចំតារាង**

# វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**The Economics and Finance Institute of the Ministry of Economy and Finance**

EFI, St. 134, Phsar Depo II, Toul Kork, Phnom Penh; Tel:(855)23 885 855, Fax:(855)23 882 121, E-mail:efi@mef.gov.kh


លេខ : ១០៧/២៣ វសហ

## សេចក្តីជូនដំណឹង

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់មន្ត្រីរាជការ ដែលត្រូវបានចាត់បញ្ជូនមកទទួលការបណ្តុះបណ្តាលក្នុងវគ្គ **“ជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង”** សម្រាប់ឆ្នាំ ២០២៣ មេត្តាជ្រាបថា បន្ទាប់ពីមន្ត្រីរាជការទទួលបានការអនុញ្ញាតឱ្យមកទទួលការបណ្តុះបណ្តាលដោយប្រធានស្ថាប័ន សាមីខ្លួនត្រូវបំពេញពាក្យសុំចូលរៀន និង បញ្ជូនមកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២៣ ដោយភ្ជាប់មកជាមួយនូវឯកសារ និង លក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ÷

**១. ឯកសារភ្ជាប់មកជាមួយ**

- ប្រវត្តិរូបសង្ខេប (បញ្ជាក់ពីអង្គភាពគ្រប់គ្រងបុគ្គលិក ឬ ប្រធានអង្គភាព, តាមគំរូដូចមានជូនភ្ជាប់),
- រូបថតថ្មី ៤x៦ ចំនួន ២ សន្លឹក,
- លិខិតតាំងស៊ប់ក្នុងក្របខណ្ឌ ឬ ប្រកាសទទួលស្គាល់មន្ត្រីជាប់កិច្ចសន្យា,
- លិខិតតែងតាំងក្នុងមុខតំណែងបច្ចុប្បន្ន (មុខតំណែងក្នុងមុខងារសាធារណៈ),
- ប្រកាស ឬ សេចក្តីសម្រេច ឬ ដីកា ដែលបញ្ជាក់ពីការតែងតាំងជា រជ្ជទេយ្យករបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានរង រជ្ជទេយ្យករចំណូល រជ្ជទេយ្យករចំណូលរង ក្រុមការងារគ្រប់គ្រងវិនិយោគសាធារណៈ ក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, **ឬ សេចក្តីបញ្ជាក់របស់ប្រធានអង្គភាព ដែលបញ្ជាក់ថាកំពុងបម្រើការងារពាក់ព័ន្ធនឹងជំនាញដែលត្រូវសិក្សា** (តាមគម្រូដូចមានជូនភ្ជាប់),
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សំបុត្រកំណើត (ថតចម្លង), និង
- លិខិតអនុញ្ញាតឱ្យមកទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**២. លក្ខណៈវិនិច្ឆ័យ**

មន្ត្រីរាជការ ដែលត្រូវបានចាត់បញ្ជូនដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង (Certificate Program) ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម÷

**២.១. សម្រាប់វគ្គបណ្តុះបណ្តាល កម្រិត ១**

- ជារជ្ជទេយ្យករបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានរង រជ្ជទេយ្យករចំណូល រជ្ជទេយ្យករចំណូលរង ក្រុមការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ឬ ក្រុមការងារបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ជាមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ, មន្ត្រីជាប់កិច្ចសន្យា ឬ បុគ្គលិកជាប់កិច្ចសន្យា ដែលកំពុងបម្រើការងារពាក់ព័ន្ធនឹងជំនាញដែលត្រូវសិក្សាតាមជំនាញខាងលើ ដោយមានសេចក្តីបញ្ជាក់ពីប្រធានអង្គភាពសាមី
- *មិនធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើមុខជំនាញឯកទេសខាងលើ ដែលបានរៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២២ ។*

**២.២. សម្រាប់វគ្គបណ្តុះបណ្តាល កម្រិត ២**

- ជាមន្ត្រីរាជការ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង (Certificate Program) **កម្រិត ១** ក្នុងឆ្នាំ ២០២៣ ដោយជោគជ័យ
- មានសេចក្តីបញ្ជាក់ពីប្រធានអង្គភាពសាមី អនុញ្ញាតឱ្យបន្តការសិក្សានៅក្នុងវគ្គបណ្តុះបណ្តាល កម្រិត ២ ។

**៣. កាលបរិច្ឆេទចូលរៀន**

វគ្គទី ១ : ចាប់ផ្តើមថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២៣ បញ្ចប់ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២៣ ។

វគ្គទី ២ : ចាប់ផ្តើមថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០២៣ បញ្ចប់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ ។

វគ្គទី ៣ : ចាប់ផ្តើមថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០២៣ បញ្ចប់ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២៣ ។

វគ្គទី ៤ : ចាប់ផ្តើមថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០២៣ បញ្ចប់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២៣ ។

ថ្ងៃ ចន្ទ ១៥ កើត ខែផល្គុន ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ ២០២៣
**វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
Economics and Finance Institute

**ទំនាក់ទំនងព័ត៌មានបន្ថែម ៖**

១. កញ្ញា នួន ចារីរ ៖ ០១១ ២៣៤ ១៤៤

២. កញ្ញា ម៉ាណ ម៉ារីណែត ៖ ០១០ ៣៩១ ១៩៦

៣. កញ្ញា ប៉ាត ស៊ុមប៉ិច ៖ ០៨១ ២៥៥ ៥៥២

## ពិធីប្រកាសបើកវគ្គបណ្តុះបណ្តាលស្តីពី

## "ជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ឆ្នាំ ២០២៣"

ថ្ងៃ ចន្ទ ៥ កើត ខែ ពិសាខ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២៣

នៅសណ្ឋាគារ ............................ រាជធានីភ្នំពេញ

| ម៉ោង | កម្មវិធី |
|---|---|
| *០៨:០០-០៨:៣០* | *ការចុះឈ្មោះរបស់សិក្ខាកាម និង ភ្ញៀវកិត្តិយស* |
| *០៨:៣០-០៨:៣៥* | *ប្រកាសហេតុ និង គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា* |
| *០៨:៣៥-០៨:៥០* | *របាយការណ៍ និង មតិស្វាគមន៍របស់:*<br>*ឯកឧត្តម **អិន អេម** នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* |
| *០៨:៥០-០៩:២០* | *សុន្ទរកថាបើក និង មតិសំណេះសំណាលរបស់:*<br>*ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* |
| *០៩:២០-០៩:២៥* | *ចប់ពិធីបើកវគ្គបណ្តុះបណ្តាល និង ឆ្លងចូលកម្មវិធីបន្ត* |
| *០៩:២៥- ១០:០០* | *បទបង្ហាញ នៃការរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស កម្រិតវិញ្ញាបនបត្រ ផ្សារភ្ជាប់មុខតំណែង ឆ្នាំ ២០២៣ ដោយក្រុមការងាររបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ* |

*បញ្ជាក់: សូមរក្សាសិទ្ធិក្នុងការកែសម្រួលកម្មវិធីក្នុងករណីចាំបាច់ ។*